វេទិកាពលរដ្ឋ

FORUM FOR THE PEOPLE

ពលរដ្ឋខ្លាំង ជាតិខ្លាំង

STRONG PEOPLE STRONG NATION

សហរដ្ឋអាមេរិក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២

# សេចក្តីថ្លែងការណ៍

## រដ្ឋាភិបាលត្រូវធ្វើសមាជជាតិ ឲ្យប្រជាពលរដ្ឋចូលរួមមតិ អំពីវិសោធនកម្មរដ្ឋធម្មនុញ្ញ

**វេទិកាពលរដ្ឋ** មើលឃើញច្បាស់ថា វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០នេះ មិនត្រឹមតែប៉ះពាល់ប៉ុណ្ណោះទេ ប៉ុន្តែ បំពានយ៉ាងកំរោល ចំពោះ**ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ** ឬ **របបសភានិយម** នៅកម្ពុជា។

យើងខ្ញុំ ក៏ធ្លាប់ចេញសេចក្តីថ្លែងការណ៍ និងបកស្រាយបំភ្លឺថា ការកែរដ្ឋធម្មនុញ្ញនេះ មានគោលដៅត្រឹមតែជាការអនុវត្ត**ផែនការនយោបាយផ្ទេរអំណាច**ពីលោក **ហ៊ុន សែន** ទៅលោក **ហ៊ុន ម៉ាណែត** ប៉ុណ្ណោះ មិនមែនដើម្បីបម្រើបុព្វហេតុជាតិ និង ឧត្តមប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ ដែលជាម្ចាស់ប្រទេសកម្ពុជាឡើយ។

ឆ្លើយតបនឹង**សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងយុត្តិធម៌ នៅថ្ងៃទី២៩ ខែកក្កដា** ដែលបានបង្ហាញសមានចិត្តអញ្ជើញគណបក្សនយោបាយ និង អង្គការសង្គមស៊ីវិល ឲ្យទៅចុះឈ្មោះចូលស្តាប់ការបកស្រាយដដែលៗរបស់ក្រសួងយុត្តិធម៌នោះ **វេទិកាពលរដ្ឋ** យល់ឃើញថា រដ្ឋាភិបាលគួរតែរៀបចំ**សមាជជាតិ** ជាជំនួសវិញ និងក៏ជាវិធីប្រសើរជាង ដើម្បីឲ្យសង្គមស៊ីវិល គណបក្សនយោបាយ និង ជាពិសេស ប្រជាពលរដ្ឋដែលជាម្ចាស់វាសនាជាតិ បានចូលរួមសម្តែងមតិ និង លើកឡើងនូវកង្វល់នានារបស់ពួកគាត់។

**ការធ្វើសមាជជាតិ** ឲ្យប្រជាពលរដ្ឋខ្មែរទូទៅ ចូលរួមស្តាប់និងមានយោបល់ មានប្រយោជន៍ធំធេងណាស់ ៖

**១.** ជាការគោរពស្មារតីរដ្ឋធម្មនុញ្ញ ស្តីពី**សមាជជាតិ** ក្នុងជំពូកទី១៤ថ្មីទាំងមូល ដែលបើកឲ្យប្រជាពលរដ្ឋ ជ្រាបដោយផ្ទាល់អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកបញ្ហានិងសំណូមពរ ជូនរដ្ឋអំណាចដោះស្រាយ។

**២.** ជាការផ្តល់តម្លៃដល់ការចូលរួមរបស់ប្រជាពលរដ្ឋ ស្របតាមគោលការណ៍ប្រតិបត្តិជាក់ស្តែង ក្នុងសង្គមប្រជាធិបតេយ្យ។

**៣.** កាត់បន្ថយការចំណាយពេលច្រើនរបស់រដ្ឋាភិបាល ដែលនឹងត្រូវពន្យល់ច្រំដែល លើចម្ងល់ដូចៗគ្នា ពីមជ្ឈដ្ឋានផ្សេងៗគ្នា។

**៤.** ជាវេទិកាសាធារណៈ ដែលបង្ហាញតម្លាមតិ និង ជម្រះគ្រប់សេចក្តីមន្ទិលសង្ស័យ ពីគ្រប់មជ្ឈដ្ឋាន។

ប៉ុន្តែការអនុញ្ញាតឲ្យគណបក្សនយោបាយ និងសង្គមស៊ីវិល ចុះឈ្មោះចូលស្តាប់អ្នកដឹកនាំក្រសួងយុត្តិធម៌ របៀបមិនសាធារណៈបែបនេះ នៅតែរងការចោទប្រកាន់ពីគ្រប់ទិសនិងមជ្ឈដ្ឋាននានា ចៀសមិនផុតឡើយ ថាជាល្បិចឬលេសដោះសាក្នុងផែនការនយោបាយលាក់ពុតរបស់រដ្ឋាភិបាល ដែលកំពុងដឹកនាំប្រទេស។

**វេទិកាពលរដ្ឋ** លើកទឹកចិត្តឲ្យរដ្ឋាភិបាល មានសេចក្តីក្លាហាន រៀបចំ**សមាជជាតិ** កុំបិទបាំងពីប្រជាពលរដ្ឋ ទើបជាផលល្អ ក្នុងការស្តារមុខមាត់រដ្ឋាភិបាលផង បម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋផង និង ឆ្លើយតបឧត្តមប្រយោជន៍ជាតិ នៃរបស់ដែលហៅថា ការប្រតិបត្តិនយោបាយសង្គមប្រជាធិបតេយ្យសេរីពហុបក្សបរិសុទ្ធ ដោយស្មារតីសុចរិត មិនបំពានឆន្ទៈរបស់ប្រជាពលរដ្ឋផង។

**ប្រធាន វេទិកាពលរដ្ឋ**

**គឹម សុខ**

Address: 58 Poplar Street, Plains PA 18 705, USA